Kingdom of Cambodia

# អ៊ុនដាហ្វ ២០១៦-២០១៨

## ក្របខណ្ឌជំនួយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ

United Nations in Cambodia

អ៊ុនដាហ្វ២០១៦-២០១៨ ឆ្លុះបញ្ចាំងការតម្រង់ទិសជាយុទ្ធសាស្ត្រសម្រាប់ប្រព័ន្ធអ.ស.ប.ប្រចាំកម្ពុជា។ អ៊ុនដាហ្វមានសុខដុមនីយកម្មជាមួយដំណើរការធ្វើផែនការជាតិ និងមានវិសាលភាពគ្របដណ្តប់រយៈពេលបីឆ្នាំ ស្របគ្នាទៅនឹងក្របខណ្ឌពេលវេលារបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨។ វាត្រូវបានគេតាក់តែងឡើងតាមរយៈដំណើរការពិគ្រោះយោបល់គ្នាយ៉ាងសកម្ម និងមានសមិទ្ធផលបីដែលបំពេញឲ្យគ្នាទៅវិញទៅមក។

## បញ្ហាអន្តរវិស័យ

- ចីរភាពបរិស្ថាន
- សមភាពយេនឌ័រ
- សិទ្ធិមនុស្ស
- យុវជន

## ការប៉ាន់ប្រមាណធនធានចាំបាច់ *

៣ ឆ្នាំ




* ព័ត៌មានគិតត្រឹមខែធ្នូ ឆ្នាំ២០១៥




### សមិទ្ធផលទី ១ : កំណើនប្រកបដោយបរិយាប័ន្ន និងការអភិវឌ្ឍដោយចីរភាព

ដល់ឆ្នាំ ២០១៨ ប្រជាជនរស់នៅប្រទេសកម្ពុជា ពិសេសយុវជន ស្ត្រី និងក្រុមប្រជាជនងាយរងគ្រោះ មានលទ្ធភាពចូលរួមយ៉ាងសកម្មក្នុង និងទទួលបានអត្ថប្រយោជន៍ប្រកបដោយសមធម៌ ពីកំណើន និងការអភិវឌ្ឍដែលមានចីរភាព ហើយដែលមិននាំឲ្យខូចខាតដល់សុខមាលភាពធនធានធម្មជាតិ និងវប្បធម៌សម្រាប់មនុស្សជំនាន់ក្រោយ។

### សមិទ្ធផលទី ២ : កិច្ចអភិវឌ្ឍន៍សង្គម កិច្ចគាំពារសង្គម និងមូលធនមនុស្ស

ដល់ឆ្នាំ ២០១៨ ប្រជាជនកាន់តែច្រើនថែមទៀត ពិសេសប្រជាជនងាយរងគ្រោះ ប្រជាជនក្រីក្រ និងអ្នកដែលមិនសូវទទួលបានការយកចិត្តទុកដាក់ នឹងទទួលបានដោយសមធម៌ នូវប្រយោជន៍ និងចូលរួមចំណែកផងដែរ ពីការកិច្ចគាំពារនិងសេវាកម្មសង្គមប្រកបដោយគុណភាពនិងចីរភាព និងទទួលបានការពង្រីកជំនាញ ដើម្បីឈានទៅសម្រេចបាននិងរួមវិភាគទានដល់ការអភិវឌ្ឍសង្គម និង មនុស្ស។

### សមិទ្ធផលទី ៣ : អភិបាលកិច្ច និងសិទ្ធិមនុស្ស

ដល់ឆ្នាំ ២០១៨ ស្ថាប័នជាតិនិងថ្នាក់ក្រោមជាតិកាន់តែមានតម្លាភាព និងគណនេយ្យភាពជាងមុន ចំពោះវិស័យកំណែទម្រង់សំខាន់ៗ និងចំពោះនីតិរដ្ឋ មានការឆ្លើយប្រសើរជាងមុនទៅនឹងវិសមភាពក្នុងការទទួលបានសិទ្ធិមនុស្សរបស់ប្រជាជនទាំងអស់ ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា និងបង្កើនការចូលរួមរបស់ពលរដ្ឋក្នុងការធ្វើសេចក្តីសម្រេចតាមបែបប្រជាធិបតេយ្យ។

## គោលការណ៍ស្នូលនៃកម្មវិធីអភិវឌ្ឍន៍

- អភិក្រមផ្អែកលើសិទ្ធិមនុស្ស
- ចីរភាពបរិស្ថាន
- ការកសាងសមត្ថភាព
- សមភាពយេនឌ័រ
- ការគ្រប់គ្រងផ្អែកលើលទ្ធផល

## ភាគីពាក់ព័ន្ធសំខាន់ៗ

- រាជរដ្ឋាភិបាលកម្ពុជា
- អង្គការសហប្រជាជាតិ
- សង្គមស៊ីវិល
- ដៃគូអភិវឌ្ឍន៍
- វិស័យឯកជន
- សហគមន៍នៅទូទាំងប្រទេសកម្ពុជា

អ៊ុនដាហ្វ២០១៦-២០១៨ត្រូវបានរៀបចំ និងអនុវត្តដោយផ្អែកលើបទពិសោធន៍ និងមេរៀនពីការអនុវត្តអ៊ុនដាហ្វមុនៗ។ វាអនុលោមតាមគោលការណ៍ណែនាំស្តង់ដារបស់អ.ស.ប. ដែលសំដៅធានាឲ្យបាននូវសង្គតិភាព គុណភាព និងការផ្តោតលើការឆ្លើយតបទៅនឹងវិស័យអទិភាពជាតិ។ អ៊ុនដាហ្វគាំទ្រដល់ការអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាព ដោយផ្អែកលើលទ្ធផល និងមេរៀនទាំងឡាយនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។